ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៥២៥ [illegible] កសក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
ចូល
លេខ 206
ថ្ងៃទី 26/04/2017
បញ្ជូន

# សេចក្តីជូនដំណឹង
## ស្តីពី
## លក្ខខណ្ឌតម្រូវនៃការនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វពីបរទេស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់ក្រុមហ៊ុន និងអាជីវករដែលទទួលបានគោលការណ៍អនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វ ដើម្បីផ្គត់ផ្គង់បំពេញតម្រូវការសាច់នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត ក្រុង ជ្រាបថា ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យនៃការឆ្លងរាលដាលនៃជំងឺសត្វ លើកកម្ពស់គុណភាពសាច់សត្វ និងការពារសុខុមាលភាពសាធារណៈប្រកបដោយសុវត្ថិភាពនោះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងចាត់ចែងពង្រឹងការអនុវត្តវិធានការអនាម័យស្របតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ បទដ្ឋានគតិយុត្ត និងគោលការណ៍ស្តង់ដារអនាម័យសត្វផលិតផលសត្វ ដែលតម្រូវឱ្យមានការត្រួតពិនិត្យដល់ប្រភពដើមពីគណៈកម្មការគ្រប់គ្រង និងវាយតម្លៃហានិភ័យរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជាមុនសិន ដើម្បីជាមូលដ្ឋានក្នុងការអនុញ្ញាតឱ្យនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វមកផ្គត់ផ្គង់បំពេញតម្រូវការទីផ្សារក្នុងប្រទេសកម្ពុជា។

ក្នុងបរិការណ៍នេះ ក្រុមហ៊ុន និងអាជីវករដែលមានបំណងស្នើសុំ និងបន្តគោលការណ៍អនុញ្ញាតនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វ ត្រូវចាត់ចែងបំពេញតាមនីតិវិធី និងលក្ខខណ្ឌដូចខាងក្រោម៖

- ជាក្រុមហ៊ុនស្របច្បាប់ដែលបានចុះបញ្ជីពាណិជ្ជកម្ម និងមានប័ណ្ណប៉ាតង់សុពលភាព
- ត្រូវមានទីតាំងប្រមូលផ្តុំសត្វនៅចំណុចដើមទី និងចំណុចចុងទី ដែលទទួលស្គាល់ដោយសមត្ថកិច្ចជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រូវមានកិច្ចសន្យាផ្គត់ផ្គង់សត្វរស់ ឬសាច់សត្វ ឬផលិតផលសត្វពីកសិដ្ឋាន ឬក្រុមហ៊ុនស្របច្បាប់នៃប្រទេសនាំចេញ
- ត្រូវអនុវត្តតាមប្រកាសលេខ២២៧ ប្រក.កសក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីបែបបទនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វក្នុងស្រុក
- ត្រូវចុះកិច្ចសន្យាបច្ចេកទេសជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវធានាអនុវត្តកិច្ចសន្យានេះឱ្យបានត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស
- ត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យប្រភពដើមនៃសត្វរស់ សាច់សត្វ និងផលិតផលសត្វ។

ទទួលបានសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុន និងអាជីវករដែលកំពុង ឬមានបំណងនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វពីបរទេស ត្រូវបំពេញបែបបទ និងទំនាក់ទំនងដើម្បីទទួលការណែនាំបន្ថែមនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកសារ កាលប្បវត្តិ